ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និង ទិសដៅការងារឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា
នៅធនាគារជាតិនៃកម្ពុជា, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥

**សូមគោរព៖**

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

នៅពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់យើង បានប្រព្រឹត្តទៅដោយរលូននិងឈានដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អង្គសន្និបាតយើងបានបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាលបំផុត ហើយសមាជិកសមាជិកានៃអង្គសន្និបាតយើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗ អនុសាសន៍ណែនាំ និងដំណោះស្រាយថ្មីៗទាក់ទងនឹងបញ្ហាប្រឈម ជាពិសេស ក្តាប់បាននូវផែនការសកម្មភាពសម្រាប់យកទៅអនុវត្តឱ្យចំគោលដៅ និងមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានធ្វើបទអន្តរាគមន៍និងផ្តល់អនុសាសន៍ណែនាំល្អៗ ជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកគ្រប់ថ្នាក់ទាំងអស់ ដែលបានអញ្ជើញចូលរួម និងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ៗ នៃអង្គសន្និបាត ដើម្បីយកទៅបំពេញភារកិច្ចឱ្យសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ។

**- គណៈអធិបតី!**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

តាមរយៈរបាយការណ៍និងបទអន្តរាគមន៍ក្នុងរយៈពេលពីរថ្ងៃនេះ ខ្ញុំបានសង្កេតឃើញថា អង្គសន្និបាតរបស់យើងបានប្រព្រឹត្តទៅយ៉ាងសកម្ម ដោយផ្តោតលើចំណុចសំខាន់ៗដូចតទៅ ៖



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**១/- ស្ថានភាពសេដ្ឋកិច្ច និងសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា ៖** កាលពីម្សិលមិញ លោកជំទាវ ជា សិរី បានជម្រាបជូនអង្គសន្និបាតអំពីស្ថានភាពសេដ្ឋកិច្ចនិងសមិទ្ធផលនៃការដឹកនាំគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ ការត្រួតពិនិត្យនិងពង្រឹងសុវត្ថិភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងការវិនិយោគទុនបម្រុងអន្តរជាតិ ការងារសវនកម្មផ្ទៃក្នុង និងអភិបាលកិច្ច ការគ្រប់គ្រងនិងពង្រឹងសុវត្ថិភាពប្រតិបត្តិការធនាគារកណ្តាល ការងារលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងកិច្ចសហប្រតិបត្តិការអាស៊ាន ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការងារទំនាក់ទំនងអន្តរជាតិជាដើម ។ ជារួម នៅក្នុងឆ្នាំ២០១៤ កន្លងមក វិស័យធនាគារនិងហិរញ្ញវត្ថុមានសុវត្ថិភាពនិងមានភាពរឹងមាំ ហើយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពនិងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយសេដ្ឋកិច្ចជាតិមានអត្រាកំណើនជាមធ្យម ៨% ។ ទាំងនេះ គឺជាសមិទ្ធផលនិងជាមោទនភាពរួម ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នានៅទូទាំងប្រទេស របស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងកិច្ចសហប្រតិបត្តិការល្អពីក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាលផងដែរ ។

សមិទ្ធផលទាំងនេះ ពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព រក្សាបាននូវស្ថិរភាពថ្លៃ និងបានរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ ការសម្រេចបាននូវគោលដៅនៃកំណើន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺទាមទារឱ្យមានការរួមចំណែកពីអាជ្ញាធរពាក់ព័ន្ធក្នុងការបន្តពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអនុវត្តគោលនយោបាយគាំទ្រមួយចំនួនទៀត ដូចជា ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការគ្រប់គ្រងនិងបែងចែកធនធានមនុស្សប្រកបដោយសមភាពនិងប្រសិទ្ធភាព ផងដែរ ។

ចំពោះការអភិវឌ្ឍវិស័យធនាគារវិញ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗសម្រាប់ឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាបានអនុវត្ត និងត្រូវធ្វើនាពេលអនាគត ដូចតទៅ៖

**២/- ការពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារ** : ឯកឧត្តម គិម វ៉ាដា និង លោក វ័ត្ន សុវណ្ណនរៈ បានជម្រាបជូនអង្គសន្និបាតរួចហើយ អំពីការរីកចម្រើននៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេស អំពីវិធីសាស្ត្រថ្មីៗនិងយន្តការដែលយើងអនុវត្ត ដើម្បីពង្រឹងសុខភាព និងសុវត្ថិភាពប្រព័ន្ធធនាគារនៅកម្ពុជា។ សុវត្ថិភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពដែល

យើងត្រូវពង្រឹងជាប់ជាប្រចាំ តាមរយៈការដាក់ចេញនូវវិធានការទាំងផ្នែកម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ន ដើម្បីត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានណាដែលអាចបង្កហានិភ័យជាប្រព័ន្ធ ។

ដើម្បីសម្រេចបានគោលដៅនេះ ខ្ញុំស្នើសុំឱ្យអគ្គនាយកដ្ឋានត្រួតពិនិត្យ និងមន្ត្រីពាក់ព័ន្ធចូលរួមពិនិត្យ កែលម្អប្រព័ន្ធត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិថ្មីៗ ស្របតាមការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ និងស្តង់ដារអភិក្រមជាតិ-អន្តរជាតិ ។ យើងក៏ត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករ និងពង្រឹងវិធីសាស្ត្រនៃការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ ទស្សនៈអនាគត និងការត្រួតពិនិត្យគួបសរុប បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្ន ។ ខ្ញុំសូមឱ្យយកចិត្តទុកដាក់តាមដាន ដោះស្រាយបញ្ហាធនាគារស្រមោល និងប្រែក្លាយការប្រើប្រាស់ប្រភពហិរញ្ញវត្ថុមិនផ្លូវការមកជាការប្រើប្រាស់ផ្លូវការ តាមរយៈការចុះបញ្ជី និងសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះផងដែរ សំដៅលើកទឹកចិត្តការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយវិជ្ជាជីវៈ និងមានកម្រៃសមរម្យជូនប្រជាពលរដ្ឋ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ក៏មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង ។ ទន្ទឹមនឹងការរីកចម្រើននេះ ក៏មានបញ្ហាប្រឈមខ្លះដែរ ជាបញ្ហានៅតាមបណ្តាខេត្តមួយចំនួនដែរ ។ ថ្មីៗនេះ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចចេញសេចក្តីថ្លែងការរួម ដើម្បីទប់ស្កាត់និងការពារហានិភ័យជាយថាហេតុ ជូនប្រជាពលរដ្ឋយើងនៅតាមតំបន់ជនបទ ។ ក្រៅពីការពង្រឹងការងារត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាយើងត្រូវ ១/- បង្កើនប្រសិទ្ធភាពតួនាទីការិយាល័យឥណទាន ២/- ពង្រឹងក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣/- បង្កបរិយាកាសប្រកួតប្រជែងលើអត្រាការប្រាក់ សេវា និងផលិតផលហិរញ្ញវត្ថុ និង ៤/- ពង្រីកលទ្ធភាពប្រើប្រាស់ឥណទានចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។

ដើម្បីរួមចំណែកដោយដោះស្រាយបញ្ហានេះ ខ្ញុំសូមស្នើសុំឱ្យ ឯកឧត្តម គិម វ៉ាជា ថ្នាក់ដឹកនាំនិងនាយកសាខាធនាគារជាតិនៃកម្ពុជា ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធចូលរួមអនុវត្តសេចក្តីថ្លែងការណ៍រួមរបស់ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ចូលរួមសហការរៀបចំវេទិកាសាធារណៈ ដើម្បីផ្សព្វផ្សាយការយល់ដឹងបញ្ហានេះនៅតាមខេត្តមួយចំនួនបន្ថែមទៀត ។

**៣/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច៖** ខ្ញុំសូមឯកភាពតាមមតិ លោកជំទាវ ស្រី ស៊ីយុត ដែលបានជម្រាបជូនអង្គសន្និបាតយើង ។ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចមាន សារៈសំខាន់ណាស់ សម្រាប់ពង្រឹងអភិបាលកិច្ចល្អ ប្រសិទ្ធភាពការងារ និងសុវត្ថិភាពធនាគារ កណ្តាល ដូច្នេះខ្ញុំស្នើសុំឱ្យអគ្គាធិការដ្ឋានបន្តចុះតាមដានការអនុវត្ត តាមអនុសាសន៍ដែល បានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក និងពង្រឹងការងារ អធិការកិច្ច ទាំងនៅទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្តបន្តទៀត ។

ដើម្បីបន្តអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពនិងទទួលបានជោគជ័យបន្ថែមទៀត តម្រូវឱ្យនាយកដ្ឋាននិងអង្គភាពនានាផ្តល់កិច្ចសហការ ហើយទាមទារឱ្យមន្ត្រីបុគ្គលិក យើងត្រូវពង្រឹងស្មារតីទទួលខុសត្រូវចំពោះការងារ គោរពវិន័យ និងខិតខំអភិវឌ្ឍខ្លួនឱ្យដើរ ទាន់ការប្រែប្រួលនៃស្ថានភាពការងារបច្ចុប្បន្ន ជាពិសេស ស្របតាមស្តង់ដារអន្តរជាតិ ។ លទ្ធផលរបស់របាយការណ៍សវនកម្មផ្ទៃក្នុង មានសារៈសំខាន់ណាស់សម្រាប់វាយតម្លៃពី ភាពរឹងមាំ សុវត្ថិភាព តម្លាភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ស្រប តាមគោលការណ៍អភិបាលកិច្ចល្អ ហើយលទ្ធផលនេះ ជាធាតុចូលនិងជាព័ត៌មានសម្រាប់ របាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិ និងជូនរាជរដ្ឋាភិបាលទៀតផង ។

**៤/- ការងារអគ្គបេឡា៖** ខ្ញុំសូមឯកភាពតាមមតិរបស់ ឯកឧត្តម ថា យ៉ាវ និង លោកស្រី អ៊ិច សុខុម ទាក់ទងនឹងការងារគ្រប់គ្រងសាច់ប្រាក់ និងឃ្លាំងបេឡា ។ បញ្ហាមួយដែលខ្ញុំ ចាប់អារម្មណ៍ គឺបញ្ហាក្រដាសប្រាក់ក្លែងក្លាយបានថយចុះជាច្រើន ហើយការដឹកជញ្ជូន ធនបត្រមានការរីកចម្រើនយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ បន្ទាប់ពីយើងបានកែលម្អសាខា ធនាគារជាតិនៃកម្ពុជានៅតាមខេត្តឡើងវិញ ។ ដើម្បីបង្កើនប្រសិទ្ធភាពការងារបន្តទៀត ខ្ញុំស្នើសុំឱ្យមន្ត្រីទាំងអស់បង្កើនសមត្ថភាពបច្ចេកទេស ការងារឃ្លាំងបេឡា គឺជាការងារ បច្ចេកទេសទាក់ទងនឹងការបោះផ្សាយ ការគ្រប់គ្រងឃ្លាំងបេឡា និងការតាមដានបរិមាណ រូបិយវត្ថុទូទៅនៅក្នុងសេដ្ឋកិច្ច ។ ក្រៅពីនេះ ការងារនេះទាមទារឱ្យមានការគោរពវិន័យនិង ការចាត់តាំង មានស្មារតីទទួលខុសត្រូវ ភាពស្មោះត្រង់ និងមានការតស៊ូអត់ធ្មត់ចំពោះការងារ។

ដោយសារ វិន័យជារឿងសំខាន់សម្រាប់មន្ត្រីបុគ្គលិកទាំងអស់គ្នា ដូច្នេះ ខ្ញុំសូមឱ្យ គ្រប់នាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវពង្រឹងវិន័យការងារ ការបំពេញមុខងារនិងភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវ ហើយត្រូវចាត់តាំងឱ្យមាន មន្ត្រីប្រចាំការ នៅរាល់ថ្ងៃចុងសប្តាហ៍និងថ្ងៃបុណ្យ ដើម្បីថែរក្សាការពារនូវសុវត្ថិភាពទ្រព្យ សម្បត្តិយើងកុំឱ្យបាត់បង់ ឬបង្ការក្រែងមានហេតុការណ៍ណាមួយកើតឡើងដោយថៃដន្យ អាចដោះស្រាយបានទាន់ពេលវេលា ។

**៥/- ចំពោះការងារគណនេយ្យ IT និងប្រព័ន្ធទូទាត់** ៖ ខ្ញុំសូមឯកភាពតាមរបាយការណ៍របស់ លោក អ៊ូ ចាន់តារា ដែលបានលើកឡើងថា បច្ចុប្បន្ន ប្រតិបត្តិការទូទាត់សងប្រាក់មានដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM, Easy Cash និងការទូទាត់តាមទូរសព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុ ។ យើងបានបោះផ្សាយមូលបត្រអាចជួញដូរបាន (NCD) កាលពីចុងឆ្នាំ២០១៣ ហើយនៅឆ្នាំ ២០១៤ ឧបករណ៍ហិរញ្ញវត្ថុថ្មីៗ មានការីកចម្រើនដោយមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានវិនិយោគសន្ទនីយភាពរយៈពេលខ្លីលើឧបករណ៍ NCD នេះ ហើយមាននិន្នាការកើនឡើងជាលំដាប់ ។ ការងារនេះមានការវិវត្តរីកចម្រើនយ៉ាងខ្លាំង ហើយមានការលំបាកខ្លាំងណាស់ដែរ ប៉ុន្តែ យើងអាចជម្នះបានការលំបាកនោះបានតាមរយៈការរៀនបណ្តើរ-ធ្វើការងារបណ្តើរ ។

ប្រតិបត្តិការទាំងនេះ គឺជាការងារបច្ចេកទេស មានលក្ខណៈវិទ្យាសាស្ត្រ ហើយប្រើប្រាស់បច្ចេកវិទ្យា IT ទំនើបចុងក្រោយបំផុត ដែលតម្រូវឱ្យអ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់ឧបករណ៍នេះ មានចំណេះដឹងបច្ចេកទេស ស្មារតីទទួលខុសត្រូវខ្ពស់ តស៊ូ និងភាពអត់ធ្មត់បំផុត ចំពោះរាល់ប្រតិបត្តិការ និងគ្រប់ពេលវេលាទាំងអស់ ។ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃទំហំប្រតិបត្តិការ យើងបានអភិវឌ្ឍនិងធ្វើទំនើបកម្មប្រព័ន្ធទូទាត់ តាមរយៈការបង្កើតនូវនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ និងចាត់តាំងក្បាលម៉ាស៊ីនដឹកនាំ និងមន្ត្រីបច្ចេកទេសដើម្បីជាកិច្ចដំណើរការការងារនេះផងដែរ ។

ដើម្បីអនុវត្តការងារក្នុងផ្នែកនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ខ្ញុំស្នើសុំឱ្យនាយកដ្ឋានជំនាញដូចជា នាយកដ្ឋានគណនេយ្យសហការជាមួយអគ្គាធិការដ្ឋាន នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត បន្តបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ខ្លួន ទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្តជាប់ជាប្រចាំ ទាំងផ្នែកក្របខ័ណ្ឌច្បាប់ និងវិធីសាស្ត្រថ្មីៗ ដើម្បីណែនាំពីរបៀបប្រើប្រាស់ (User guides) ការប្រើប្រាស់ប្រព័ន្ធទូទាត់ផ្ទាល់ ជាលក្ខណៈអន្តរធនាគារ រវាងធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភ្នាក់ងារប្រតិបត្តិករផ្សេងទៀត និងសូមឱ្យធនាគារជាតិនៃកម្ពុជា សាខារាជធានី-ខេត្ត មានការប្រុងប្រយ័ត្នក្នុងការអនុវត្តនិងប្រើប្រាស់ប្រព័ន្ធ Flexcube និងការគោរពនីតិវិធីនៃការចុះបញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ។

**៦/- ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា៖** លោកជំទាវ សាយ សំអាត បានជម្រាបជូនអង្គសន្និបាតអំពីសមិទ្ធផលការងារដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រេចបានក្នុងការងារប្រឆាំងការសម្អាតប្រាក់ ។ តាមរយៈការអភិវឌ្ឍរីកចម្រើនថ្មីៗនេះ ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ អង្គភាពនេះត្រូវបានអនុញ្ញាតឱ្យចូលជាសមាជិកពេញសិទ្ធិនៃក្រុមប្រទេស Egmont Group ។ ដូច្នេះ យើងត្រូវត្រៀមលក្ខណៈចាត់តាំងគណៈប្រតិភូទៅទទួល ។

ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ និងសហគមន៍អន្តរជាតិ ខ្ញុំសូមស្នើសុំឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបន្តពង្រីកយន្តការ សហប្រតិបត្តិការ និងការងារអនុវត្តច្បាប់ជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិបន្តទៀត ។

**៧/- ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ៖** ដូច លោក យូ វុណ្ណី បានលើកឡើងថា បញ្ហាដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា មិនមែនកើតឡើងដោយឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលទេ គឺកើតឡើងដោយសារកត្តាប្រវត្តិសាស្ត្របន្សល់ទុក និងការបាត់បង់ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិ ។ បញ្ហានេះ បានក្លាយទៅជាបញ្ហាម៉ាក្រូសេដ្ឋកិច្ចជាតិ តម្រូវឱ្យយើងរួមគ្នាដោះស្រាយដោយសន្សឹមៗ នឹងប្រុងប្រយ័ត្នបំផុត ។ បញ្ហាដុល្លារូបនីយកម្មនៅកម្ពុជា មានបូក និងមានដក ពោលគឺមានគុណសម្បត្តិនិងគុណវិបត្តិចំពោះសេដ្ឋកិច្ចជាតិនិងសង្គម ។ ចំពោះវិធានការអនុវត្តរបស់អាជ្ញាធរ យើងថ្លឹងថ្លែងបំផុតពីការចំណេញ ខាត ក្របខ័ណ្ឌច្បាប់ និងវិធានរដ្ឋបាល ការដាក់ចេញនូវផែនការសកម្មភាព និងរយៈពេល ពីផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនិងបញ្ហានយោបាយ ។ កន្លងមក ធនាគារជាតិនៃកម្ពុជា រួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម បានអនុវត្តវិធានការពង្រឹងការប្រើប្រាស់ប្រាក់រៀល ទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ដូចជា ការបើកប្រាក់ខែជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ការបង់ពន្ធ និងការទូទាត់ថ្លៃទឹក-ភ្លើង ដោយធ្វើឡើងជាប្រាក់រៀល ។

បច្ចុប្បន្ន យើងសង្កេតឃើញថា ប្រាក់រៀលគឺជាឧបករណ៍ចាំបាច់បំផុត ក្នុងជីវភាពរស់នៅនិងការងារប្រចាំថ្ងៃបច្ចុប្បន្ន ។ តាមរយៈការស្រាវជ្រាវបានបង្ហាញថា សាធារណជនទូទៅ ជាពិសេស ប្រជាជននៅតាមជនបទបានប្រើប្រាស់ប្រាក់រៀលយ៉ាងច្រើន ។ និន្នាការនៃការប្រើប្រាស់ប្រាក់រៀលបានកើនឡើងយ៉ាងទូលំទូលាយ ក្នុងសកម្មភាពសេដ្ឋកិច្ច ។ សូចនាករនេះ អាចឆ្លុះបញ្ចាំងតាមរយៈកំណើនរូបិយវត្ថុក្នុងចរាចរណ៍ ដែលបានកើនឡើងជារៀងរាល់ឆ្នាំ ។ ដោយសារសារៈសំខាន់នៃរូបិយវត្ថុជាតិ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល បានរំលេចយ៉ាងច្បាស់ពីការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជា បានដើរតួនាទីជាលេខាធិការឱ្យ

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំឯកសារផែនការយុទ្ធសាស្ត្រជាតិស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា ឆ្នាំ២០១៥-២០២០ ។ ឯកសារនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងបានបញ្ជូនទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ ។

ដើម្បីពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល និងពង្រឹងរចនាសម្ព័ន្ធប្រាក់រៀល ការបែងចែក និងការដាក់ប្រាក់រៀលនៅក្នុងចរាចរណ៍ ធនាគារជាតិនៃកម្ពុជាបានបោះធនបត្រប្រភេទតូចនិងធំ ក្នុងគោលបំណងដើម្បីសម្រួលដល់ការដោះដូរ ទូទាត់ពាណិជ្ជកម្មនិងជាឧបករណ៍សន្សំរបស់ប្រជាជន ។ ដូច ឯកឧត្តម ថា យ៉ាវ និង ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានជម្រាបជូនអង្គសន្និបាតយើងអញ្ចឹង ប្រាក់រៀលយើងតំណាងឱ្យអធិបតេយ្យភាពនិងអំណាចសេដ្ឋកិច្ចរបស់រដ្ឋ ។ រូបភាពដែលយើងប្រើនៅលើក្រដាសប្រាក់ ដើម្បីបង្ហាញពីការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចនិងសង្គម ពីប្រវត្តិសាស្ត្រ វប្បធម៌ និងសាសនា ព្រឹត្តការណ៍នយោបាយនិងសកម្មភាពសេដ្ឋកិច្ចជាតិជាដើម ។ ចំពោះរូបភាព ដែលយើងប្រើនៅលើក្រដាសប្រាក់ប្រភេទមួយរយរៀលគំរូថ្មីនេះ គឺតំណាងឱ្យជាតិ សាសនា និងព្រះមហាក្សត្រ ។ ហើយការយកព្រះសម្មាសម្ពុទ្ធមកប្រើ គឺដើម្បីបញ្ជាក់ឱ្យប្រជាជនយើងដឹងថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ការយករូបព្រះពុទ្ធមកដាក់នៅលើរូបិយវត្ថុជាតិនេះ គឺជាការលើកតម្កើង ការគោរព និងជំនឿព្រះពុទ្ធសាសនារបស់យើង ។ ការយករូបព្រះសម្មាសម្ពុទ្ធមកប្រើ មិនមែនមានតែប្រទេសកម្ពុជាប៉ុណ្ណោះទេ មានប្រទេសជាច្រើននៅលើពិភពលោកក៏បានប្រើរូបព្រះ រូបអាទិទេព និងរូបឥស្សរជនរបស់គេ ដើម្បីធ្វើជានិមិត្តរូបនៃការគោរព និមិត្តរូបនៃតម្លៃ និងនិមិត្តរូបនៃជំនឿក្នុងសាសនា ហើយត្រូវបានគេប្រើជាយូរយារណាស់មកហើយដែរ ដូច ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានបញ្ជាក់មុននេះ ។

ដើម្បីឱ្យអង្គសន្និបាត ជាពិសេស មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា មានទស្សនៈរួមលើប្រាក់រៀលនេះ ខ្ញុំស្នើសុំឱ្យយកមតិ ឯកឧត្តម អគ្គលេខាធិការ និង ឯកឧត្តម អគ្គបេឡា យកទៅផ្សព្វផ្សាយ និងជម្រាបជូនប្រជាជនទូទៅយល់ច្បាស់អំពីបញ្ហានេះ ។

**៨/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក ៖** ដូច ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានបញ្ជាក់ថា ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សគឺជាការងារសំខាន់សម្រាប់ស្ថាប័ន និងប្រទេសជាតិ ព្រោះការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ បច្ចុប្បន្ន យើងមានយន្តការបណ្តុះបណ្តាលជាប់ជាប្រចាំ ទាំងក្នុងនិងក្រៅប្រទេស ។ ក្នុងប្រទេស យើងបានរៀបចំក្រោមរូបភាពនៃការផ្ទេរនិងចែករំលែកចំណេះដឹងនិងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងប្រធានបទម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយរូបិយវត្ថុ ការត្រួតពិនិត្យធនាគារ និងជាអ្នកដឹកនាំប្រតិបត្តិការធនាគារកណ្តាល ។ ជាមួយគ្នានេះ យើងក៏

បានបញ្ជូនមន្ត្រីឱ្យចូលរួមសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនៅតាមក្រសួង-ស្ថាប័ននានាផងដែរ ។ នៅក្រៅប្រទេស សម្រាប់ការបណ្តុះបណ្តាលរយៈពេលខ្លី យើងមានដៃគូអភិវឌ្ឍន៍ក្នុងតំបន់និងអន្តរជាតិ ដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាល IMF, ADB, WB, SEACEN, ASEAN, ASEAN+3, មជ្ឈមណ្ឌល Toronto និងបណ្តាធនាគារកណ្តាលជាដៃគូនៅក្នុងតំបន់មួយចំនួនទៀត ។ ចំណែកឯការបណ្តុះបណ្តាលរយៈពេលវែង យើងបានធ្វើឡើងក្រោមកម្មវិធីអាហារូបករណ៍រដ្ឋាភិបាល និងធនាគារកណ្តាលជាមិត្តមួយចំនួន ទាំងក្នុងតំបន់ និងជុំវិញពិភពលោក ព្រមទាំងស្ថាប័នអន្តរជាតិមួយចំនួនផងដែរ ។ ក្រៅពីនេះ យើងបានរៀបចំកម្មវិធីបណ្តុះបណ្តាលក្រោមរូបភាពជា E-learning ដើម្បីឱ្យការបណ្តុះបណ្តាលនិងអភិវឌ្ឍមន្ត្រីត្រួតពិនិត្យនិងមន្ត្រីជំនាញផ្សេងទៀត ។

យើងត្រូវបណ្តុះបណ្តាលមន្ត្រីលើផ្នែកជំនាញឯកទេសកម្ម ដើម្បីកសាងកម្លាំងបន្តវេន និងបន្តនិរន្តរភាពការងាររបស់យើងនៅពេលអនាគត ខណៈដែលថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើង កំពុងចូលនិវត្តន៍ជាបណ្តើរៗ ។ ការបណ្តុះបណ្តាលរបស់យើងមានគ្រប់រូបភាពទាំងនៅក្នុងនិងក្រៅប្រទេស លើផ្នែកជំនាញឯកទេសកម្មនិងផ្នែកគុណធម៌ ។ ជាលទ្ធផលយើងទទួលបានមន្ត្រីដែលមានសមត្ថភាពជំនាញជាបន្តបន្ទាប់ និងបានជួយការងាររបស់យើងសម្រេចបានសមិទ្ធផលល្អប្រសើរ ។

ដើម្បីបន្តអនុវត្តការងារបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យអគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានពាក់ព័ន្ធ ជាពិសេស នាយកដ្ឋានបុគ្គលិកត្រូវរៀបចំយន្តការនិងកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ហើយសូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សារៀនសូត្របន្ថែម ទាំងផ្នែកភាសានិងជំនាញឯកទេស ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត ។

៩/- **ការពង្រឹងប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត៖** ការងារនេះគឺជាការងារអាទិភាពរបស់យើងផង ហើយក៏ជាយន្តការជំរុញការប្រើប្រាស់ ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផង និងជាការរួមចំណែកក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី៣ ផង ។ សាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត ក្នុងនាមជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរបស់រដ្ឋ និងជាធនាគាររបស់រដ្ឋ ។ ការងារសំខាន់ៗរបស់យើងគឺការគ្រប់គ្រងសាច់ប្រាក់ ការបើកគណនីនិងគ្រប់គ្រងសេវាគណនីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សំដៅជួយសម្រួលចរាចរណ៍សាច់ប្រាក់ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ការទូទាត់ពាណិជ្ជកម្ម ការបង់ពន្ធអាករ និង ការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទូទាំងប្រទេស ។

ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវពង្រឹងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួនឱ្យស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់នោះផង និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងដែនដីរដ្ឋបាល ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀល ឱ្យប្រព្រឹត្តទៅដោយរលូននិងកាន់តែទូលំទូលាយថែមទៀត ហើយត្រូវសហការជាមួយអគ្គនាយកដ្ឋានត្រួតពិនិត្យ ដើម្បីរៀបចំវេទិកាផ្សព្វផ្សាយសាធារណៈ និងដើរតួនាទីជាអាជ្ញាធរត្រួតពិនិត្យផ្នែករដ្ឋបាល លើចំនួនសាខា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មក្នុងខេត្តរបស់ខ្លួន ។

**១០/- ការងារសហប្រតិបត្តិការអន្តរជាតិ** : ការងារនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការមិត្តភាព និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងប្រតិបត្តិការធនាគារកណ្តាល ។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាបាន ១/- ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមិត្តភាពជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, ADB, WB និងធនាគារកណ្តាល ក្នុងតំបន់និងពិភពលោក ២/- លើកកម្ពស់កិត្យានុភាព និងតួនាទីធនាគារជាតិនៃកម្ពុជានៅក្នុងតំបន់និងឆាកអន្តរជាតិ ៣/- ជំរុញការធ្វើសមាហរណកម្មវិស័យធនាគារនៅកម្ពុជាចូលទៅក្នុងតំបន់និងពិភពលោក និង ៤/- លើកកម្ពស់ការបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ និងផ្លាស់ប្តូរយោបល់ពីការងារគ្រប់គ្រងធនាគារកណ្តាល និងការដឹកនាំនយោបាយរូបិយវត្ថុ ឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិនិងតំបន់។

ដោយឡែក ចំពោះការងារអាស៊ានវិញ កន្លងមកធនាគារជាតិនៃកម្ពុជា បានគាំទ្រនិងចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមនានា របស់អាស៊ាន សំដៅរួមចំណែកនៅក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅចុងឆ្នាំ២០១៥នេះ ។ ដូចដែល លោក យូ វុណ្ណឹ បាន លើកឡើង ទន្ទឹមនឹងអត្ថប្រយោជន៍ដែលកម្ពុជាអាចទទួលបាន ដូចជា ការមានមូលដ្ឋានផលិតកម្មក្នុងទីផ្សារតែមួយ ការលើកកម្ពស់ការប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ចដោយសមភាព និងការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅទៅក្នុងពិភពលោក កម្ពុជាក៏ជួបបញ្ហាប្រឈមមួយចំនួនផងដែរ ។ ដូច្នេះ ដើម្បីរួមចំណែកសម្រេចបានគោលដៅរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន និងដោះស្រាយបញ្ហាប្រឈមទាំងនេះ ខ្ញុំសូមស្នើឱ្យនាយកដ្ឋានពាក់ព័ន្ធនានានិងក្រុមការងារបច្ចេកទេសរបស់ធនាគារជាតិនៃកម្ពុជាទាំងអស់ បន្តខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពជាប់ជាប្រចាំ និងរៀនសូត្រពីបទពិសោធន៍ពីបណ្តាប្រទេសជាមិត្ត ក្នុងការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឱ្យកាន់តែរឹងមាំ និងមានភាពប្រកួតប្រជែងខ្ពស់ ។

ខ្ញុំស្នើសុំឱ្យមន្ត្រីបុគ្គលិករបស់យើង បន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាល និងដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀត ។

- **គណៈអធិបតី**

- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

សរុបមក ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃ កម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹងប្រព័ន្ធធនាគារទាំងមូលឱ្យប្រព្រឹត្តទៅដោយរលូននិងមានសុវត្ថិភាព ។ មតិដែលខ្ញុំបានលើកឡើងខាងលើនេះខ្លីៗទេ បើសិនចង់ដឹងលម្អិតបន្ថែមទៀត សូមពិនិត្យក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់យើងបន្ថែមទៀត ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅការងារ និងភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយ នៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួន នូវខ្លឹមសារនិងអនុសាសន៍ល្អៗ ដើម្បីអនុវត្តចំពោះការងារប្រចាំថ្ងៃ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត

២/- រួមចំណែកពង្រឹងនិងពង្រីកការអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយ និងមានប្រិសទ្ធភាព

៣/- សូមមន្ត្រីបុគ្គលិករបស់យើងបន្តរក្សានូវស្មារតីសាមគ្គីគ្នាជាប្រពៃណី ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត និង

៤/- បន្តអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើន សម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិនិងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះ

ការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀត និង កាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរ ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**!